ធ៧-០៤-០៣៧ ប្រ.ក

# ប្រកាស
# ស្តីពី
# ការទូទាត់សងជាមុននូវប្រាក់ថ្លៃឈ្នួលនិងភតិសន្យា

**ប្រការ ១**.-

ធនាគារត្រូវបានអនុញ្ញាតឱ្យទូទាត់សងប្រាក់ថ្លៃឈ្នួល ឬភតិសន្យាលើទ្រព្យសម្បត្តិដោយត្រូវគោរពតាមលក្ខណៈវិនិច្ឆ័យមួយចំនួនដូចខាងក្រោម។

**ប្រការ ២**.-

ទ្រព្យសម្បត្តិដែលបានជួលឬភតិសន្យាត្រូវបម្រើឱ្យប្រតិបត្តិការផ្ទាល់របស់ធនាគារ។ ធនាគារមិនត្រូវបានអនុញ្ញាតឱ្យជួល ប្រសិនបើទ្រព្យសម្បត្តិនោះមិនត្រូវបានប្រើប្រាស់ សម្រាប់សកម្មភាពចាំបាច់របស់ធនាគារទេ។

**ប្រការ ៣**.-

យោងតាមគោលការណ៍នៃខ្លឹមសារមានទម្ងន់លើទម្រង់ ការជួលឬភតិសន្យាដែលបានទូទាត់មុនមិនអាចត្រូវបានប្រើសម្រាប់ដកប្រាក់ពីធនាគារទេហើយជាពិសេសមិនអាចត្រូវបានប្រើសម្រាប់ដកដើមទុនផ្ទាល់របស់ភាគ-ទុនិកឡើយ។

**ប្រការ ៤**.-

ការជួលឬភតិសន្យាដែលបានទូទាត់មុនមិនត្រូវឱ្យលើសពីរយៈពេលមួយឆ្នាំនៃថ្លៃជួលទ្រព្យសម្បត្តិឡើយ។

**ប្រការ ៥**.-

ប្រសិនបើធនាគារត្រូវតំកល់ប្រាក់ធានា ឬត្រូវផ្តល់ឥណទានក្នុងចំនួនណាមួយឱ្យម្ចាស់ទ្រព្យសម្បត្តិនោះ គឺជាចំនួនប្រាក់ដែលបានទូទាត់រួចកត់ត្រានៅក្នុងតារាងតុល្យការ ហើយចំនួនប្រាក់នោះមិនត្រូវលើសពីមួយឆ្នាំនៃថ្លៃជួលទ្រព្យសម្បត្តិទេ។

**ប្រការ ៦**.-

ចំនួនប្រាក់ដែលបានទូទាត់រួចទាំងអស់ លើសពីប្រាក់ថ្លៃជួលទ្រព្យសម្បត្តិមួយឆ្នាំនឹងត្រូវកាត់ចេញពីមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។

**ប្រការ ៧**.-

ក្នុងករណីប្រាក់ថ្លៃជួលដែលបានទូទាត់ជាមុនលើការជួល ឬភតិសន្យាមានរយៈពេលតិចជាងមួយឆ្នាំ ក៏ប៉ុន្តែមានតម្លៃខ្ពស់ជាងថ្លៃទីផ្សារ គំលាតរវាងប្រាក់ថ្លៃជួលដែលបានទូទាត់មុនលើការជួល ឬភតិសន្យាជាមួយថ្លៃទីផ្សារនឹងត្រូវបានដកចេញពីមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។

**ប្រការ ៨**.-

ការជួលឬភតិសន្យាជាមួយសម្ព័ន្ធញាតិត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសស្តីពីការផ្តល់ឥណទានទៅឱ្យសម្ព័ន្ធញាតិ។ ថ្លៃជួលទ្រព្យសម្បត្តិ ដែលបានទូទាត់ឱ្យសម្ព័ន្ធញាតិដែលនៅសល់ និងប្រាក់ជួល ឬភតិសន្យាដែលទូទាត់មុននឹងត្រូវបានបញ្ចូលទៅក្នុងប្រតិវេទន៍ប្រចាំត្រីមាស ស្តីពី ឥណទានដែលបានផ្តល់ឱ្យសម្ព័ន្ធញាតិ។

**ប្រការ ៩**.-

ធនាគារដែលមានប្រាក់ថ្លៃជួលឬភតិសន្យាដែលបានទូទាត់មុនលើសពីមួយឆ្នាំ នឹងត្រូវបានទុកពេលឱ្យអនុវត្តតាមប្រកាសនេះក្នុងរយៈពេលប្រាំមួយខែ។ ផុតរយៈពេលនេះប្រាក់ថ្លៃជួល ឬភតិសន្យាដែលបានទូទាត់មុនលើសពីមួយឆ្នាំ នឹងត្រូវបានកាត់ចេញពីមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។

**ប្រការ ១០**.-

ទោះបីជាមានប្រការទី ៦ និងប្រការទី ៨ ក៏ដោយធនាគារដែលមិនអនុវត្តបានតាមខ្លឹមសារនៃប្រកាសនេះ នឹងត្រូវទទួលរងការផាកពិន័យតាមមាត្រាទី៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ១១**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ១២**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែមិនា ឆ្នាំ២០០៤

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**